**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត**
**ព្រៃវែង**

សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៣៣៧
ចុះថ្ងៃទី ១៣ ខែ ធ្នូ
ឆ្នាំ ២០០៤

**សាលក្រម**
លេខ : ១៦
ចុះថ្ងៃទី ០៧ ខែ តុលា
ឆ្នាំ ២០០៩

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តព្រៃវែង**

បានបើកសវនាការ នៅថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៩
និង ប្រកាសសាលក្រម នៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៩
ដោយមានសមាសភាព ជំនុំជំរះដូចតទៅ ៖
ប្រធានក្រុមប្រឹក្សាជំនុំជំរះ លោក [redacted] ជាចៅក្រមសាលាដំបូង ខេត្តព្រៃវែង
ចៅក្រមប្រឹក្សា លោក [redacted] ជាអនុប្រធានសាលាដំបូង ខេត្តព្រៃវែង
ចៅក្រមប្រឹក្សា លោក [redacted] ជាចៅក្រមសាលាដំបូង ខេត្តព្រៃវែង
តំណាងអយ្យការ លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូង ខេត្តព្រៃវែង
ក្រឡាបញ្ជីសវនាការ លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូង ខេត្តព្រៃវែង

**<u>ដើម្បីជំនុំជម្រះ</u>**

សំណុំរឿងព្រហ្មទណ្ឌលេខ ៣៣៧ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលមាន ៖

១-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៤៣ឆ្នាំ មានទីលំនៅបច្ចុប្បន្ន [redacted] កើតនៅភូមិកណ្តាច់ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង មុខរបរធ្វើស្រែ ។

២-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ឆ្នាំ មានទីលំនៅបច្ចុប្បន្ន [redacted] កើតនៅភូមិកណ្តាច់ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង មុខរបរធ្វើស្រែ ។

ឈ្មោះ [redacted] និងឈ្មោះ [redacted] ត្រូវបានចោទពីបទមនុស្សឃាតដោយចេតនាប្រព្រឹត្តនៅភូមិមានជ័យ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង កាលពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ។ បទល្មើសដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផល ភេទប្រុស អាយុ ៤៥ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិ កណ្តាច់ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង កើតនៅភូមិមានជ័យ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង មុខរបរធ្វើស្រែ ។

មេធាវីលោក [redacted] ការពារអោយជនជាប់ចោទ
មេធាវីលោកស្រី [redacted] ការពារអោយដើមបណ្តឹង
ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ ៖

Scanned with CamScanner

កាលពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ វេលាម៉ោងដប់ពីរយប់ ឈ្មោះ [redacted] បានបបួលឈ្មោះ [redacted] ទៅផឹកស៊ីនៅផ្ទះឈ្មោះ [redacted] រហូតដល់ម៉ោង ៣.៣០ នាទី ស្រាប់តែត្រូវឈ្មោះ [redacted] ភា ស្លាប់ ។ ហើយក្រោយមក នៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឈ្មោះ [redacted] និងឈ្មោះ [redacted] ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន ។ ឈ្មោះ [redacted] និង ឈ្មោះ [redacted] បានបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នេះទេ ។

បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជំរះលេខ ៨៤៥ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩ របស់ចៅក្រម ស៊ើបសួរសាលាដំបូងខេត្តព្រៃវែង ។

## នាពេលសវនាការ

១-ជនជាប់ចោទ ឈ្មោះ [redacted] បានឆ្លើយថា នៅក្នុងថ្ងៃកើតហេតុនោះ ខ្លួនពុំបានវាយទៅលើ ឈ្មោះ [redacted] ភា នោះទេ ឈ្មោះ [redacted] ភា ស្លាប់ដោយសារតែឡានរបស់ឈ្មោះ [redacted] បើកទៅបុក ។

២-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា ខ្លួនពិតជាបានបើកឡានជ្រុលចង្កូតទៅបុកឈ្មោះ [redacted] ភា បណ្តាលអោយស្លាប់មែន ។

ចំលើយសាក្សីឈ្មោះ [redacted] ផល បំភ្លឺក្នុងសវនាការថា ក្នុងយប់ ថ្ងៃកើតហេតុនោះវេលាម៉ោងប្រហែល ២រំលង អធ្រាត ខ្លួនបានដើរមកផ្ទះខ្លួនដើម្បីមកយកប្រេងចាក់ម៉ាស៊ីនក៏បានឃើញឡានបត់ចូលផ្ទះឈ្មោះ [redacted] ខ្លួនក៏ដើរមក ឈប់មើលនៅពីមុខផ្ទះ [redacted] ក៏បានឃើញ [redacted] ភា ចុះពីលើផ្ទះមក ហើយស្រាប់តែឃើញឈ្មោះ [redacted] វាយទៅលើ ឈ្មោះ [redacted] ភា ដោយដំបង ហើយភ្លើងក្នុងឡានក៏បានបិទ ខ្លួនមិនបានមើលឃើញអ្វីទៀតទេ ។ ចំងាយពីខ្លួនទៅកន្លែង កើតហេតុ ប្រហែល ៣០ម៉ែត្រ ។

-នៅក្នុងពេលសវនាការសាក្សីឈ្មោះ [redacted] ស្រ៊ី បានបំភ្លឺថា : នៅយប់ ថ្ងៃកើតហេតុពេលខ្លួនកំពុងដេក នៅម៉ោងប្រហែល បីយប់ក៏លឺពួកក្មេងស្រីស្រែកថាឡានបុកអាភាស្លាប់ហើយជួយផង ខ្លួនក៏បានលោតចុះពីលើផ្ទះទៅឃាត់ ឡាន ឃើញឈ្មោះ [redacted] បើកឡានរត់គេចចេញទៅបាត់ ។ ក្នុងពេលឡានបុកឈ្មោះ ភា ខ្លួនមិនបានឃើញផ្ទាល់ភ្នែកទេ ។

-ក្នុងពេលសវនាការសាក្សីឈ្មោះ [redacted] ស្រ៊ីម បានបំភ្លឺថា : នៅយប់ ថ្ងៃកើតហេតុនោះ ខ្លួនបានឃើញឈ្មោះ [redacted] ភា ឈរអោយឡាន ក្នុងពេលនោះដែរខ្លួនត្រូវបានយាយហៅទៅផ្ទះ ពេលដើរបានពាក់កណ្តាលផ្លូវស្រាប់តែលឺគេស្រែក ថា : ឡានបុកអាភាស្លាប់ហើយ ខ្លួនក៏ត្រលប់មកឃើញឈ្មោះ ភា បានស្លាប់ទៅហើយ ។

-តាមចំលើយសាក្សីឈ្មោះ [redacted] ស្រីម៉ៅ ក្នុងពេលសវនាការថា : នៅយប់ ថ្ងៃកើតហេតុនោះខ្លួនបានឃើញ ឈ្មោះ [redacted] បានបើកឡានចូលផ្ទះ ហើយបុកឈ្មោះ [redacted] ភា ចំពីមុខឡានត្រូវចំក្បាលបណ្តាលអោយឈ្មោះ [redacted] ភា ស្លាប់ភ្លាម ។

-ក្នុងពេលសវនាការសាក្សីឈ្មោះ [redacted] ហ៊ីរ៉ាឌី បានបំភ្លឺថា : នៅយប់ ថ្ងៃកើតហេតុនោះខ្លួនបានចូលរួមផឹកស៊ី នៅផ្ទះឈ្មោះ [redacted] ក្រោយមកខ្លួនបានជូនឈ្មោះ [redacted] ដែលស្រវឹងស្រាទៅផ្ទះវាវិញ ពេលទៅដល់ខ្លួន និងឈ្មោះ

Scanned with CamScanner

[redacted]ភារី កំដើរទៅដេកនៅរោងចិញ្ចឹមត្រី ឯឈ្មោះ [redacted] បើកឡានត្រឡប់មកផ្ទះ [redacted] វិញ លុះស្អែកឡើងទើបខ្លួនលឺគេនិយាយថា ឈ្មោះភា បានស្លាប់ហើយដោយសារឡានបុក ។

-អំណានកំនត់ហេតុពិនិត្យស្នាមរបួសលើជនរងគ្រោះឈ្មោះ [redacted] ភា បានបង្ហាញថា [redacted] ភា មានស្នាមរបួសដូចខាងក្រោម :

១-ក្បាលបែកចេញខួរ

២-ស្នាមដាច់លើស្បែក ក ក ផ្នែកខាងមុខ

៣-ស្នាមដាច់ស្បែករបកត្រង់កំភួនដៃខាងឆ្វេង

៤-ស្នាមជាំក្រោមឃ្លៀកខាងឆ្វេង គ្មានកន្ទួល គ្មានដាច់របកស្បែក

៥-ស្នាមជាំផ្នែកខាងក្រោយខ្នង ពីក្បាលមកមានជាំតូចៗ គ្មានដាច់ គ្មានកន្ទួល ។

លោកតំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន នាពេលសវនាការនេះថា : មានពិរុទ្ធគ្រប់គ្រាន់លើឈ្មោះ [redacted] និងឈ្មោះ [redacted] ពីបទមនុស្សឃាតដោយចេតនាប្រព្រឹត្តនៅភូមិមានជ័យ ឃុំចុងអំពិល ស្រុកកញ្ច្រៀច ខេត្តព្រៃវែង កាលពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ពិតប្រាកដមែន ហេតុនេះសុំអោយតុលាការធ្វើការផ្តន្ទាទោសជនល្មើសទៅតាមផ្លូវច្បាប់ ។

-លោកមេធាវីការពារអោយជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា : សុំអោយតុលាការសំរេចអោយកូនក្តីខ្លួនរួចផុតពីបទចោទ ព្រោះកូនក្តីខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។

-លោកស្រីមេធាវីការពារអោយដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការនេះថា : សុំអោយតុលាការធ្វើការផ្តន្ទាទោសជនល្មើសតាមផ្លូវច្បាប់ ។

-ក្រោយពីបានស្តាប់ចំលើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចំលើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចំលើយសាក្សីបំភ្លឺ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារដើមបណ្តឹង

-ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

-ក្រោយពីបានឆ្លងកាត់ការសួរដេញដោល

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្ត ព្រៃវែង

-យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៤៣ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ឆ្នាំ ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រៃវែងបញ្ជូនមកជំនុំជំរះពីបទមនុស្សឃាតដោយចេតនា

ប្រព្រឹត្តនៅភូមិមានជ័យ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង កាលពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ គប្បីតុលាការធ្វើការពិចារណា ។

-យល់ឃើញថា ថ្វីត្បិតតែជនជាប់ចោទបានឆ្លើយបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចបទចោទប្រកាន់ក៏ដោយ ផ្អែកតាមចំលើយបំភ្លឺរបស់សាក្សី .ឯកសារភស្តុតាងផ្សេងៗដែលមានក្នុងសំណុំរឿង ជាពិសេសចំលើយរបស់សាក្សីឈ្មោះ [redacted] ផល .ស្លាកស្នាមរបួសរបស់ឈ្មោះ [redacted] ភា ដែលមាននៅពេលនោះ វាពុំស៊ីសង្វាក់គ្នាទៅនិងរបួសស្នាមនៅពេលដែលរថយន្តបុក។ ក្រុមប្រឹក្សាជំនុំជំរះយល់ថា អំពើមនុស្សឃាតដោយចេតនាប្រព្រឹត្តនៅភូមិមានជ័យ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង កាលពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ លើជនរងគ្រោះឈ្មោះ [redacted] ភា ពិតជាប្រព្រឹត្តដោយឈ្មោះ [redacted] និងឈ្មោះ [redacted] ប្រាកដមែន ។ អំពើនេះល្មើសនិងមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ គប្បីតុលាការពិចារណាក្នុងការសំរេចសេចក្តី ។

-យល់ឃើញថា ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ [redacted] ផល ដែលត្រូវជាឪពុកបង្កើតរបស់ជនរងគ្រោះឈ្មោះ [redacted] ភា ហើយប្តឹងទាមទារសំណងជំងឺចិត្តចំនួន ៥០ ០០០ ០០០ ៛ (ហាសិបលានរៀល) មានលក្ខណៈត្រឹមត្រូវ គប្បីតុលាការពិចារណាសំរេចតាមស្ថានភាពជាក់ស្តែង។

-យល់ឃើញថា វត្ថុដែលចាប់យកមានម៉ូតូ ០២គ្រឿងម៉ាកវេវ C 100 ពណ៌បៃតងពាក់ស្លាកលេខ ភ.ព 1L 8211 និងម៉ាក C 100 កូរ៉េពណ៌ស្វាទុំលេខម៉ាស៊ីន CT 100 E 1998799 គប្បីសំរេចប្រគល់អោយម្ចាស់វិញ ។

-យល់ឃើញថា ការតំកល់បទចោទប្រកាន់របស់តំណាងអយ្យការក្នុងសវនាការមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ ។

-យល់ឃើញថា សេចក្តីសន្និដ្ឋានរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-យល់ឃើញថា មេធាវីការពារជនជាប់ចោទបានសំណូមពរសុំអោយតុលាការសំរេចអោយកូនក្តីខ្លួនបានរួចផុតពីបទចោទដោយអាងថា កូនក្តីខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ គឺពុំមានភស្តុតាងណាអាចអោយ តុលាការទទួលមកពិចារណាបានឡើយ ។

យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] និង [redacted] បានសំណូមពរចុងក្រោយថា សុំអោយតុលាការរកយុត្តិធម៌អោយខ្លួនផង ។ គប្បីតុលាការធ្វើការពិចារណាសំរេច ។

**<u>ហេតុដូច្នេះសំរេច</u>**

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៦ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ១០ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ។ ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ ៤៣ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ១០ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ។ ពីបទមនុស្សឃាតដោយចេតនាប្រព្រឹត្តនៅភូមិមានជ័យ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង កាលពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ តាមមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

២-បង្គាប់អោយឈ្មោះ [redacted] និង [redacted] រួមគ្នាសងសំណងជំងឺចិត្តដល់ឈ្មោះ [redacted] ផល ជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៥ ០០០ ០០០៛ (ប្រាំលានរៀល) ការសុំលើសពីនេះបដិសេធចោល ។

Scanned with CamScanner

L ꕯ / 1

៣-វត្ថុដែលចាប់យកមានម៉ូតូ ០២គ្រឿងម៉ាកវេវ C 100 ពណ៌បៃតងពាក់ស្លាកលេខ ភ.ព 1L 8211 និងម៉ាក C 100 កូរ៉េពណ៌ស្វាទុំលេខម៉ាស៊ីន CT 100 E 1998799 ត្រូវប្រគល់អោយម្ចាស់វិញ ។

៤-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] និង [redacted] និងដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ផល ។ បើភាគីណាមិនសុខចិត្តនិងសេចក្តីសំរេចនេះ មានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃទី 17 ខែ មីនា ឆ្នាំ 2010

ក្រឡាបញ្ជី

[redacted]

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]